18.07.23
F1629

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ....០៣៣........អ.ស.ហ.ប្រក

# ប្រកាស
# ស្តីពី
# ការកំណត់ទូទៅចំពោះគ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាមុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង
- បានឃើញប្រកាសលេខ ០១៤ អ.ស.ហ.ប្រក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ស្តីពីសេវាសាធារណៈរបស់និយ័តករធានារ៉ាប់រងកម្ពុជា
- យោងតាមការចាំបាច់របស់និយ័តករធានារ៉ាប់រងកម្ពុជា

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីកាតព្វកិច្ចទូទៅចំពោះគ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ក្នុងការស្នើសុំការអនុញ្ញាត ការជូនដំណឹង និងការផ្ដល់របាយការណ៍ ដើម្បីធានាបាននូវប្រសិទ្ធភាពនិងគណនេយ្យភាពក្នុងការគ្រប់គ្រងអាជីវកម្មធានារ៉ាប់រង អាជីវកម្មអន្តរការីធានារ៉ាប់រង និងអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

វាក្យសព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះ មាននិយមន័យដូចតទៅ៖

- **គ្រឹះស្ថានធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង។
- **ក្រុមហ៊ុនធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និងក្រុមហ៊ុនធានារ៉ាប់រងបន្ត។
- **ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង** សំដៅដល់នីតិបុគ្គលដែលជួសមុខឱ្យក្រុមហ៊ុនធានារ៉ាប់រងធ្វើការណែនាំអំពីការលក់បណ្ណសន្យារ៉ាប់រង ការរៀបចំកិច្ចសន្យាធានារ៉ាប់រង ការប្រមូលបុព្វលាភ ការរៀបចំការធ្វើសំណងជាដើម ក្នុងក្របខណ្ឌកំណត់ច្បាស់លាស់នៃកិច្ចព្រមព្រៀងរវាងភ្នាក់ងារធានារ៉ាប់រងនិងក្រុមហ៊ុនធានារ៉ាប់រង ដោយទទួលកម្រៃជើងសាពីក្រុមហ៊ុនធានារ៉ាប់រងនោះ។
- **ក្រុមហ៊ុនជើងសាធានារ៉ាប់រង** សំដៅដល់នីតិបុគ្គលដែលធ្វើការក្នុងគោលដៅនៃអត្ថប្រយោជន៍របស់អ្នកត្រូវបានធានារ៉ាប់រង ផ្ដល់សេវាប្រឹក្សា ផ្ដល់ព័ត៌មានទាក់ទងនឹងប្រភេទធានារ៉ាប់រង លក្ខខណ្ឌ និងបុព្វលាភនៃកិច្ចសន្យាធានារ៉ាប់រង ធ្វើការចរចា និងរៀបចំកិច្ចសន្យាធានារ៉ាប់រង រវាងអ្នកស្នើសុំការធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រង និងលក់បណ្ណសន្យារ៉ាប់រង ដោយទទួលកម្រៃជើងសាពីក្រុមហ៊ុនធានារ៉ាប់រង និង/ឬកម្រៃប្រឹក្សាពីអតិថិជន។
- **ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង** សំដៅដល់នីតិបុគ្គលឯករាជ្យដែលមានភារកិច្ចត្រួតពិនិត្យ ផ្ទៀងផ្ទាត់ វាយតម្លៃការខូចខាតពេលមានហានិភ័យធានារ៉ាប់រងកើតឡើង និង

កំណត់ចេញនូវឯកសារសម្រាប់ជាមូលដ្ឋានឱ្យក្រុមហ៊ុនធានារ៉ាប់រងដោះស្រាយទូទាត់សំណង។ ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងធ្វើសកម្មភាពដោយទទួលថ្លៃឈ្នួលពិនិត្យពីក្រុមហ៊ុនធានារ៉ាប់រង។

- **ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនវិជ្ជាជីវៈដែលមានជំនាញវិភាគ និងគណនាហានិភ័យធានារ៉ាប់រង ដើម្បីកំណត់អត្រាបុព្វលាភធានារ៉ាប់រង។
- **ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនវិជ្ជាជីវៈដែលមានជំនាញគ្រប់គ្រង ចាត់ចែង ដោះស្រាយសំណងធានារ៉ាប់រងជំនួសឱ្យក្រុមហ៊ុនធានារ៉ាប់រង ឬគម្រោងគ្រប់គ្រង អត្ថប្រយោជន៍របស់នីតិបុគ្គលប្រតិស្រុតផ្សេងទៀត ដោយទទួលបានកម្រៃសេវាពីក្រុមហ៊ុនធានារ៉ាប់រង ឬនីតិបុគ្គលប្រតិស្រុតទាំងនោះ តាមកិច្ចព្រមព្រៀង។
- **អគ្គនាយក** សំដៅដល់បុគ្គលមានឋានៈខ្ពស់បំផុតក្នុងកម្រិតប្រតិបត្តិរបស់ក្រុមហ៊ុន ដែលត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងកិច្ចប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន។
- **ក្រុមហ៊ុនសវនកម្ម** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មចេញដោយនិយ័តករគណនេយ្យនិងសវនកម្ម។

## ជំពូកទី២
## ភាតព្វកិច្ចស្នើសុំការអនុញ្ញាត

**ប្រការ៤.-**

គ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវស្នើសុំការអនុញ្ញាតជាមុនមក **ន.ធ.ក.** ដោយភ្ជាប់ឯកសារតម្រូវតាមការកំណត់របស់ **ន.ធ.ក.** ចំពោះករណីណាមួយដូចខាងក្រោម៖

- ការផ្លាស់ប្តូរឬកែប្រែលក្ខខណ្ឌណាមួយនៃលក្ខន្តិកៈក្រុមហ៊ុន មានជាអាទិ៍ ការផ្ទេរឬលក់ភាគហ៊ុន ការបន្ថយឬបង្កើនដើមទុន
- ការបង្កើតម៉ាក ឬពាណិជ្ជនាម
- ការផ្លាស់ប្តូរនាមករណ៍ ម៉ាក ឬពាណិជ្ជនាម
- ការផ្លាស់ប្តូរទីតាំង
- ការផ្លាស់ប្តូរគេហទំព័រ
- ការបែងចែកភាគលាភ
- ករណីផ្សេងទៀតដែលតម្រូវដោយ **ន.ធ.ក.**។

កាតព្វកិច្ចស្នើសុំការអនុញ្ញាតនេះ មិនអនុវត្តចំពោះក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងដែលជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀត និងក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងដែលជាក្រុមហ៊ុនសវនកម្មឡើយ។

**ប្រការ៥ ._**

ក្រុមហ៊ុនធានារ៉ាប់រងត្រូវស្នើសុំការអនុញ្ញាតជាមុនមក **ន.ធ.ក.** ដោយភ្ជាប់ឯកសារតម្រូវតាមការកំណត់របស់ **ន.ធ.ក.** ចំពោះករណីណាមួយដូចខាងក្រោម៖

- ការផ្លាស់ប្តូរទីតាំងរបស់សាខាក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុក
- ការលក់ផលិតផលធានារ៉ាប់រង ឬការកែប្រែផលិតផលធានារ៉ាប់រង
- ការលក់ផលិតផលធានារ៉ាប់រងតាមប្រព័ន្ធអេឡិចត្រូនិក
- ការចុះកិច្ចសន្យាជាមួយភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល
- ករណីផ្សេងទៀត ដែលតម្រូវដោយ **ន.ធ.ក.**។

**ប្រការ៦ ._**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវស្នើសុំការអនុញ្ញាតតែងតាំងបុគ្គលវិជ្ជាជីវៈតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ មក **ន.ធ.ក.** មុនការបញ្ឈប់ ឬការលាឈប់របស់បុគ្គលវិជ្ជាជីវៈតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណនោះឱ្យបានមុនរយៈពេល ៣០ (សាមសិប) ថ្ងៃ ដើម្បីបន្តកាតព្វកិច្ចបំពេញលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ។

**ប្រការ៧ ._**

ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានការឯកភាពពីក្រសួងពាណិជ្ជកម្មចំពោះការផ្លាស់ប្តូរលក្ខខណ្ឌណាមួយនៃលក្ខន្តិកៈក្រុមហ៊ុន ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវផ្តល់មក **ន.ធ.ក.** នូវលក្ខន្តិកៈក្រុមហ៊ុនថ្មី។

កាតព្វកិច្ចផ្តល់លក្ខន្តិកៈថ្មីនេះ មិនអនុវត្តចំពោះក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងដែលជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀត និងក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងដែលជាក្រុមហ៊ុនសវនកម្មឡើយ។

**ប្រការ៨ ._**

**ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាតឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០(ម្ភៃ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

ចំពោះការស្នើសុំចុះកិច្ចសន្យាជាមួយភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាតឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

## ជំពូកទី៣
## ភាតព្វកិច្ចជូនដំណឹង

**ប្រការ៩ .-**

គ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវជូនដំណឹងមក **ន.ធ.ក.** ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីការផ្លាស់ប្តូរលេខទូរសព្ទ ឬអ៊ីម៉ែល របស់គ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង។

**ប្រការ១០ .-**

គ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវជូនដំណឹងមក **ន.ធ.ក.** ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីបង្កើតគេហទំព័ររបស់គ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង។

**ប្រការ១១ .-**

គ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវតែងតាំងបុគ្គលិកទំនាក់ទំនងជាមួយ **ន.ធ.ក.** និងត្រូវជូនដំណឹងមក **ន.ធ.ក.** ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ មុនធ្វើការផ្លាស់ប្តូរបុគ្គលិកទំនាក់ទំនងនោះ ដោយបញ្ជាក់ឈ្មោះ លេខទូរសព្ទ និងអ៊ីម៉ែលរបស់បុគ្គលិកទំនាក់ទំនងថ្មី។

**ប្រការ១២ .-**

គ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវជូនដំណឹងជាបន្ទាន់មក **ន.ធ.ក.** ក្នុងករណីម្ចាស់ភាគហ៊ុន ឬសហកម្មសិទ្ធិករ ឬប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាល ឬគណៈគ្រប់គ្រង ឬប្រធានសាខា ឬបុគ្គលវិជ្ជាជីវៈតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណរបស់ក្រុមហ៊ុន ឬបុគ្រសម្ព័ន្ធ ដែលនៅក្នុងអំឡុងពេលបំពេញមុខងារស្ថិតក្នុងស្ថានភាពណាមួយ ដូចខាងក្រោម៖

១. រងការស៊ើបអង្កេត ឬរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានពិរុទ្ធភាព ឬត្រូវបានផ្តន្ទាទោសដោយការប្រព្រឹត្តល្មើសនឹងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តជាធរមាននៅក្នុងយុត្តាធិការណាមួយ

២. ជាប់បណ្តឹងរដ្ឋប្បវេណីនៅក្នុងយុត្តាធិការណាមួយពាក់ព័ន្ធនឹងការអនុវត្តវិជ្ជាជីវៈក្នុងវិស័យធានារ៉ាប់រង ឬវិស័យហិរញ្ញវត្ថុ។

**ប្រការ១៣ .-**

ក្រុមហ៊ុនធានារ៉ាប់រងត្រូវជូនដំណឹងមក **ន.ធ.ក.** ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីបញ្ចប់កិច្ចសន្យាជាមួយភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល ដោយភ្ជាប់មកជាមួយនូវបណ្ណចុះបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល។

**ប្រការ១៤ .-**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងដែលជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀត និងក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងដែលជាក្រុមហ៊ុនសវនកម្ម ត្រូវជូនដំណឹងមក **ន.ធ.ក.** ក្នុងរយៈពេលយ៉ាងយូរ ៣(បី) ថ្ងៃ បន្ទាប់ពីទទួលបានការឯកភាពពីក្រសួងពាណិជ្ជកម្ម ចំពោះការផ្លាស់ប្តូរព័ត៌មានណាមួយមានជាអាទិ៍ នាមករណ៍ក្រុមហ៊ុន ម៉ាក ពាណិជ្ជនាម ទីតាំងអាជីវកម្ម គេហទំព័រក្រុមហ៊ុន ម្ចាស់ភាគហ៊ុន ប្រធានក្រុមប្រឹក្សាភិបាល អភិបាល អគ្គនាយក ការបន្ថយឬបង្កើនដើមទុនរបស់ក្រុមហ៊ុន។

**ប្រការ១៥ .-**

ក្រុមហ៊ុនជើងសាធានារ៉ាប់រង ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវបន្តសុពលភាពកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈទៅតាមទឹកប្រាក់តម្រូវ និងជំនាញវិជ្ជាជីវៈ ដូចមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៤

## ភាតព្វកិច្ចផ្តល់របាយការណ៍

**ប្រការ១៦ .-**

ក្រុមហ៊ុនធានារ៉ាប់រងត្រូវផ្តល់មក **ន.ធ.ក.** នូវរបាយការណ៍ប្រចាំខែតាមទម្រង់ដែលកំណត់ដោយ **ន.ធ.ក.** ឱ្យបានមុនថ្ងៃទី១៥ នៃខែបន្ទាប់ ដូចខាងក្រោម៖

- របាយការណ៍អំពីអាជីវកម្ម
- របាយការណ៍អំពីការទទួល និងដោះស្រាយសំណងធានារ៉ាប់រង
- របាយការណ៍ផ្សេងទៀត តាមការតម្រូវរបស់ **ន.ធ.ក.**។

**ប្រការ១៧ .-**

ក្រុមហ៊ុនធានារ៉ាប់រងត្រូវផ្តល់មក **ន.ធ.ក.** នូវរបាយការណ៍ប្រចាំត្រីមាសតាមទម្រង់ដែលកំណត់ដោយ **ន.ធ.ក.** ឱ្យបានមុនថ្ងៃទី១៥ នៃខែទី១ នៃត្រីមាសបន្ទាប់ ដូចខាងក្រោម៖

- របាយការណ៍ហិរញ្ញវត្ថុ
- របាយការណ៍លម្អិតអំពីបុព្វលាភធានារ៉ាប់រង
- របាយការណ៍លម្អិតអំពីសំណងធានារ៉ាប់រង

- របាយការណ៍អំពីការទទួល និងដោះស្រាយសំណងធានារ៉ាប់រង
- របាយការណ៍ផ្សេងទៀត តាមការតម្រូវរបស់ **ន.ធ.ភ.**។

**ប្រការ១៨ ...**

ក្រុមហ៊ុនធានារ៉ាប់រងត្រូវផ្តល់មក **ន.ធ.ភ.** នូវផែនការអាជីវកម្មនៃឆ្នាំបន្ទាប់ ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ ជារៀងរាល់ឆ្នាំ។

**ប្រការ១៩ ...**

ក្រុមហ៊ុនធានារ៉ាប់រងត្រូវផ្តល់មក **ន.ធ.ភ.** នូវរបាយការណ៍ប្រចាំឆ្នាំតាមទម្រង់ដែលកំណត់ដោយ **ន.ធ.ភ.** ឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ ដូចខាងក្រោម៖

- របាយការណ៍ហិរញ្ញវត្ថុ
- របាយការណ៍អំពីចំនួននិយោជិត
- របាយការណ៍សង្ខេបអំពីការធានារ៉ាប់រងបន្ត
- របាយការណ៍ផ្សេងទៀត តាមការតម្រូវរបស់ **ន.ធ.ភ.**។

**ប្រការ២០ ...**

ក្រុមហ៊ុនធានារ៉ាប់រងត្រូវផ្តល់មក **ន.ធ.ភ.** នូវរបាយការណ៍ប្រចាំឆ្នាំតាមទម្រង់ដែលកំណត់ដោយ **ន.ធ.ភ.** ឱ្យបានមុនថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់ ដូចខាងក្រោម៖

- របាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មឯករាជ្យរួច
- របាយការណ៍របកគំហើញរបស់ក្រុមហ៊ុនសវនកម្មឯករាជ្យ
- របាយការណ៍សវនកម្មផ្ទៃក្នុង
- របាយការណ៍លទ្ធផលត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- របាយការណ៍អំពីចំនួនម្ចាស់បណ្ណសន្យារ៉ាប់រង
- របាយការណ៍អំពីការទទួល និងដោះស្រាយសំណងធានារ៉ាប់រង
- របាយការណ៍អំពីលទ្ធផលនៃការធ្វើសវនកម្មលើយន្តការ នីតិវិធី និងដំណើរការដោះស្រាយសំណងធានារ៉ាប់រង
- របាយការណ៍ផ្សេងទៀត តាមការតម្រូវរបស់ **ន.ធ.ភ.**។

**ប្រការ២១ ...**

ក្រុមហ៊ុនធានារ៉ាប់រងត្រូវផ្តល់មក **ន.ធ.ភ.** នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនមេ ឬក្រុមហ៊ុនហ្វូលឌីង ឱ្យបានមុនថ្ងៃទី៣០ ខែមិថុនា នៃឆ្នាំបន្ទាប់។

**ប្រការ២២.-**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង និងក្រុមហ៊ុនជើងសាធានារ៉ាប់រង ត្រូវផ្តល់មក **ន.ធ.ក.** នូវរបាយការណ៍អំពីអាជីវកម្មប្រចាំខែតាមទម្រង់ដែលកំណត់ដោយ **ន.ធ.ក.** ឱ្យបានមុនថ្ងៃទី១៥ នៃខែបន្ទាប់។

**ប្រការ២៣.-**

ក្រុមហ៊ុនជើងសាធានារ៉ាប់រង ត្រូវផ្តល់មក **ន.ធ.ក.** នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសតាមទម្រង់ដែលកំណត់ដោយ **ន.ធ.ក.** ឱ្យបានមុនថ្ងៃទី១៥ នៃខែទី១ នៃត្រីមាសបន្ទាប់។

**ប្រការ២៤.-**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវផ្តល់មក **ន.ធ.ក.** នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមទម្រង់ដែលកំណត់ដោយ **ន.ធ.ក.** ឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់។

**ប្រការ២៥.-**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវផ្តល់មក **ន.ធ.ក.** នូវរបាយការណ៍ប្រចាំឆ្នាំអំពីចំនួននិយោជិតតាមទម្រង់ដែលកំណត់ដោយ **ន.ធ.ក.** ឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់។ កាតព្វកិច្ចផ្តល់របាយការណ៍នេះ មិនអនុវត្តចំពោះក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងដែលជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀត និងក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងដែលជាក្រុមហ៊ុនសវនកម្មឡើយ។

## ជំពូកទី៥
## កម្រៃសេវារដ្ឋបាល

**ប្រការ២៦.-**

គ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់ពិនិត្យសំណុំឯកសារស្នើសុំផ្លាស់ប្តូរឬកែប្រែលក្ខខណ្ឌណាមួយនៃលក្ខន្តិកៈក្រុមហ៊ុន ចំនួន ៨០០ ០០០(ប្រាំបីរយពាន់) រៀល។

**ប្រការ២៧.-**

គ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់ពិនិត្យសំណុំឯកសារស្នើសុំផ្ទេរ ឬលក់ភាគហ៊ុន ចំនួន ៨០០ ០០០ (ប្រាំបីរយពាន់) រៀល។

**ប្រការ២៨ .-**

គ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់ពិនិត្យសំណុំឯកសារស្នើសុំបង្កើតម៉ាក ឬពាណិជ្ជនាម ចំនួន ៨០០ ០០០ (ប្រាំបីរយពាន់) រៀល។

**ប្រការ២៩ .-**

គ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់ពិនិត្យសំណុំឯកសារស្នើសុំផ្លាស់ប្តូរនាមករណ៍ ឬម៉ាក ឬពាណិជ្ជនាម ចំនួន ៨០០ ០០០ (ប្រាំបីរយពាន់) រៀល។

**ប្រការ៣០ .-**

គ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់ពិនិត្យសំណុំឯកសារស្នើសុំផ្លាស់ប្តូរគេហទំព័រ ចំនួន ៨០០ ០០០ (ប្រាំបីរយពាន់) រៀល។

**ប្រការ៣១ .-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់ពិនិត្យសំណុំឯកសារស្នើសុំលក់ផលិតផលធានារ៉ាប់រងតាមប្រព័ន្ធអេឡិចត្រូនិក ចំនួន ១ ០០០ ០០០ (មួយលាន) រៀល។

**ប្រការ៣២ .-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់ពិនិត្យសំណុំឯកសារស្នើសុំចុះកិច្ចសន្យាជាមួយភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គលចំនួន ៤ ០០០ (បួនពាន់) រៀល សម្រាប់ភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល ១ (មួយ) រូប។

**ប្រការ៣៣ .-**

កម្រៃសេវារដ្ឋបាលដែលមិនមានកំណត់ក្នុងខ្លឹមសារនៃប្រកាសនេះ ត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ៣៤ .-**

កម្រៃសេវារដ្ឋបាលសម្រាប់ពិនិត្យសំណុំឯកសារអនុលោមតាមខ្លឹមសារនៃប្រកាសនេះ ត្រូវបង់ចូលគណនីរបស់ **ន.ធ.ក.** និងមិនត្រូវបានប្រគល់ឱ្យបុគ្គលស្នើសុំវិញឡើយ ទោះបីជាការស្នើសុំត្រូវបានបដិសេធក៏ដោយ។

## ជំពូកទី៦

## ទណ្ឌកម្មរដ្ឋបាល

**ប្រការ៣៥.-**

គ្រឹះស្ថានធានារ៉ាប់រង ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៩ ប្រការ១០ ប្រការ១១ ប្រការ១២ ប្រការ១៣ ប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ១៨ ប្រការ១៩ ប្រការ២០ ប្រការ២១ ប្រការ២២ ប្រការ២៣ ប្រការ២៤ និងប្រការ២៥ នៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ពី **និ.ធ.ក.**។

**និ.ធ.ក.** អាចដាក់ទណ្ឌកម្មរដ្ឋបាលណាមួយដូចខាងក្រោម៖

១. ការណែនាំ

២. ការព្រមានជាលាយលក្ខណ៍អក្សរ

៣. ការកត់សម្គាល់ជាសាធារណៈ ហើយបញ្ជាឱ្យធ្វើការកែតម្រូវ

៤. ការដាក់កំហិតលើសកម្មភាពអាជីវកម្មធានារ៉ាប់រង

៥. ការព្យួរ ឬដកហូតអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតជាគោលការណ៍

៦. ទណ្ឌកម្មរដ្ឋបាលផ្សេងទៀត ដែលកំណត់ដោយ **និ.ធ.ក.** ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មុននឹងដាក់ទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងកថាខណ្ឌខាងលើ **និ.ធ.ក.** ត្រូវផ្តល់ឱកាសឱ្យបុគ្គលប្រព្រឹត្តល្មើសធ្វើការស្រាយបំភ្លឺជាមុនសិន។

**ប្រការ៣៦.-**

ទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងជំពូកនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។

## ជំពូកទី៧

## អវសានបញ្ញត្តិ

**ប្រការ៣៧.-**

អគ្គនាយកនៃ **និ.ធ.ក.** អាចចេញគោលការណ៍ណែនាំអនុលោមតាមច្បាប់ស្តីពីការធានារ៉ាប់រង អនុក្រឹត្យស្តីពីការធានារ៉ាប់រង និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមប្រកាសនេះ។

**ប្រការ៣៨.-**

ប្រកាសលេខ ៩៣៤ សហវ.ឧហ. ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០១ ស្តីពីការកំណត់ទូទៅចំពោះប្រតិបត្តិករធានារ៉ាប់រង និងប្រកាសលេខ ១៧៦ សហវ.ឧហ. ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ ស្តីពីបទប្បញ្ញត្តិដែល

ត្រូវអនុវត្តចំពោះភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រង និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣៩.-**

អគ្គនាយកនៃ **ន.ធ.ភ.** គ្រប់ប្រធាននាយកដ្ឋានស្ថិតក្រោមចំណុះ **ន.ធ.ភ.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន គិតចាប់ពីកាលបរិច្ឆេទចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ១ កើត ខែ ទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ឯកឧត្តមនិងលោកជំទាវជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៣៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ